ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៩៦,៩៣៣ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនយោធិន សមាហរណកម្ម ព្រមទាំងគ្រួសារនៃកងពលតូចលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក ចំនួន ២០ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៦១/១៧ ល.ស ចុះថ្ងៃទី ០៥ខែ មិថុនា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- លិខិតលេខ ១៧៩១ ដនស/អសក ចុះថ្ងៃទី ២០ ខែ កក្កដា គ.ស ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៨០៥៣ កសក ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ **៩៦,៩៣៣៣ ហិកតា** ចេញពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន World Tristar Company និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនយោធិនសមាហរណកម្ម ព្រមទាំងគ្រួសារនៃកងពលតូច លេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ២០ គ្រួសារ ទំហំ **៩៤,៧៦៤២ ហិកតា** និងផ្ទៃដីទំហំ **២,១៦៩១ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូចលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក នៅភូមិជុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៤ កើត ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......២៣០ អនក្រ.បក......ចុះថ្ងៃទី......២១......ខែ......ធ្នូ......ឆ្នាំ២០១៧ ស្តីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន( World_Tristar_Company) ទំហំ ៩៦,៩៣៣៣ ហិកតា នៅភូមិជុំថ្កៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ដើម្បីស្នើសុំធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ក្នុងនោះការធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនបងប្អូនសមាហរណកម្មយោធិនព្រមទាំងគ្រួសារ ក្នុងកងពលតូចលេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ២០ គ្រួសារ និងរក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ




| ចំណុច | Y | X |
|---|---|---|
| 1 | 1211158 | 413523 |
| 2 | 1211169 | 413225 |
| 3 | 1211176 | 412596 |
| 4 | 1212319 | 412692 |
| 5 | 1212319 | 413516 |
| 6 | 1212232 | 413612 |
| 7 | 1212131 | 413520 |
| 8 | 1212057 | 413468 |
| 9 | 1212048 | 412747 |
| 10 | 1211982 | 412727 |
| 11 | 1211932 | 412694 |
| 12 | 1211932 | 412758 |
| 13 | 1211949 | 412762 |
| 14 | 1211933 | 412823 |
| 15 | 1211940 | 413482 |
| 16 | 1211703 | 413513 |
| 17 | 1211363 | 413545 |




## សញ្ញាសម្គាល់

- ភូមិ
- ឃុំ
- ដីភ្នំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៩៦.៩៣៣៣ ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ៩៤,៧៦៥២ ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ២.១៦៩១ ហិកតា
- ស្ទឹង
- ផ្លូវ

## ទិន្នន័យគម្របព្រៃឈើ២០០២

- ព្រៃស្រោង
- ព្រៃពាក់កណ្ដាលស្រោង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:13,000

0 175 350 700 1,050 1,400 Meters

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៦៣០ អនក្រ.បក.........ចុះថ្ងៃទី..២១...ខែ...មិថុនា...ឆ្នាំ២០១៧ស្តីពី ការកាត់ចេញពីផែនទីតម្រុបព្រៃឈើឆ្នាំ២០០២ និងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន(World_Tristar_Company) ទំហំ ៩៦.៩៣៣៣ ហិកតា នៅភូមិជុំថ្កៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ដើម្បីស្នើសុំធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ក្នុងនោះការធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនបងប្អូនសមាហរណកម្មយោធិនព្រមទាំងគ្រួសារ ក្នុងកងពលតូចលេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ២០ គ្រួសារ និងរក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ

N

មាត្រដ្ឋាន 1:9,638




| ចំណុច | Y | X |
|---|---|---|
| 1 | 1211158 | 413523 |
| 2 | 1211169 | 413225 |
| 3 | 1211176 | 412596 |
| 4 | 1212319 | 412592 |
| 5 | 1212319 | 413516 |
| 6 | 1212232 | 413512 |
| 7 | 1212131 | 413520 |
| 8 | 1212057 | 413468 |
| 9 | 1212048 | 412747 |
| 10 | 1211982 | 412727 |
| 11 | 1211932 | 412694 |
| 12 | 1211932 | 412758 |
| 13 | 1211949 | 412762 |
| 14 | 1211933 | 412823 |
| 15 | 1211940 | 413482 |
| 16 | 1211703 | 413513 |
| 17 | 1211363 | 413545 |

Coordinate System Projection UTM Zone 48N Map Datum:WGS84

វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត.ថ្ងៃទី..៣០.....ខែ..មករា..ឆ្នាំ២០១៧

អ្នកវាស់វែង

អ៊ុក ចាន់

លេខ.៣២១.ដ.១៧

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត ថ្ងៃទី ៣០...ខែ..មករា..ឆ្នាំ២០១៧

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

ម៉ិន-ឡុង

បានឃើញ និងឯកភាព

កំពត ថ្ងៃទី..០៥.....ខែ..មករា....ឆ្នាំ២០១៧

អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

ចាន់ ចេស្តា